**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤១៧ អនក្រ.បក

## សេចក្តីសំរេច

## ស្តីពី

## រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រង

## ស្រុកសៀមរាប នៃខេត្តសៀមរាប និង ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

## ស ំ រេ ច

**ប្រការ ១.-**

សេចក្តីសំរេចនេះ កំណត់រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាបនៃខេត្តសៀមរាប និង ស្រុកបាត់ដំបងនៃខេត្តបាត់ដំបង ដើម្បីសាកល្បងក្នុងការបង្កើតជាមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចៈអោយមានតុល្យភាព និង ចូលរួមកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ២.-**

រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងបច្ចុប្បន្ន នៃស្រុកសៀមរាប និង ស្រុកបាត់ដំបង ត្រូវធ្វើការពិនិត្យវាយតំលៃសាកល្បងរៀបចំជាជំហានៗ ឱ្យបានសមស្របតាមសភាពការណ៍ជាក់ស្តែង និង ស្របតាមស្មារតីនៃសេចក្តីសំរេចនេះ ។

**ប្រការ ៣.-**

ក្នុងការអនុវត្តនីសាកល្បង ស្រុកទាំងពីរត្រូវបំពេញតួនាទី និង មុខងារដូចខាងក្រោមនេះ ÷

**តួនាទី :**

- រដ្ឋបាលស្រុកទាំងពីរ មានតួនាទីជំរុញ និង គាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធានដែលស្រុកមាន ប្រកបដោយនិរន្តរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានរបស់ស្រុក សំដៅបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋផង និង គោរពផលប្រយោជន៍របស់ជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ ។

- ជាមណ្ឌលសាកល្បងរបស់ខេត្តក្នុងការបំរើសេចក្តីត្រូវការ និង ការផ្តល់សេវាកម្មសាធារណៈផ្សេងៗដល់ប្រជាពលរដ្ឋ ។

**មុខងារ :**

- ផ្តល់សេវាកម្មរដ្ឋបាលសាធារណៈ ដែលប្រជាពលរដ្ឋ សហគ្រាស ឬ ក្រុមហ៊ុន អាជីវករនានាត្រូវការជាចាំបាច់ក្នុងជីវភាពប្រចាំថ្ងៃ និង ក្នុងធុរកិច្ច តាមរបៀបដែលមានប្រសិទ្ធភាព មានតម្លាភាព និងចំណាយធនធានតិច ដើម្បីបង្កើតបានជាគំរូអភិបាលកិច្ចល្អ ។

- រៀបចំផែនការអភិវឌ្ឍន៍ស្រុក ដោយមានការចូលរួមរបស់ប្រជាពលរដ្ឋ ដែលមានលក្ខណៈសមស្របទៅនឹងផែនការអភិវឌ្ឍន៍ខេត្ត និង ផែនការសេដ្ឋកិច្ច សង្គមកិច្ចរបស់រដ្ឋ ដោយមានការសំរបសំរួលជាមួយផែនការអភិវឌ្ឍន៍ឃុំ ព្រមទាំងកំណត់ធនធានចាំបាច់សំរាប់អនុវត្តផែនការរបស់ខ្លួន។

- សំរបសំរួល និង គាំទ្រដល់ក្រុមប្រឹក្សាឃុំនានា នៃស្រុករបស់ខ្លួន តាមការណែនាំរបស់អភិបាលខេត្តសាមី ដើម្បីឱ្យក្រុមប្រឹក្សាឃុំអនុវត្តបានពេញលេញនូវអំណាច តួនាទី និង ភារកិច្ចដែលបានប្រគល់ឱ្យដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង លិខិតបទដ្ឋានជាធរមានផ្សេងៗ ទៀត ។

- បង្កើនប្រសិទ្ធភាព ក្នុងការអនុវត្តន៍គោលនយោបាយជាតិ និង កម្មវិធីរបស់ក្រសួងស្ថាប័ននានា នៃរាជរដ្ឋាភិបាល ក្រោមការសម្របសម្រួលពីអភិបាលខេត្តសាមី ដោយមានកិច្ចសហប្រតិបត្តិការ ជាមួយប្រជាពលរដ្ឋ ។

**ប្រការ ៤.-**

ក្នុងការអនុវត្តន៍គំរោងសាកល្បងនេះ ស្រុកទាំងពីរត្រូវបានទទួលប្រតិភូកម្មអំណាច ក្នុងនោះមានការដឹកនាំ និង/ឬ សំរបសំរួល និង/ឬ ជំរុញ និង/ឬ ត្រួតពិនិត្យក្នុងការរៀបចំប្លង់គោល ផែនការប្រើប្រាស់ ដីធ្លី

ការសាងសង់ សំណង់នានាតាមការកំណត់ ការកសាង ជួសជុល ថែទាំផ្លូវថ្នល់ ការធ្វើចរាចរ ការចុះបញ្ជី យានយន្ត អាជ្ញាប័ណ្ណ និង លិខិតអនុញ្ញាតដល់ក្រុមហ៊ុនពាណិជ្ជកម្ម សេវាកម្ម សិប្បកម្មខ្នាតតូច និង មធ្យម ការសិក្សាអប់រំ សង្គមកិច្ច វប្បធម៌ សុខាភិបាល និង ការធ្វើនីត្យានុកូលកម្ម ឬ បញ្ជាក់លើឯកសារ ព្រមទាំងឯកសារថតចម្លងផ្លូវការនានា ។

**ប្រការ ៥.–**

ការអនុវត្តនីតួនាទី មុខងារ និង អំណាច ដូចមានចែងក្នុងមាត្រា ៣ និង មាត្រា ៤ នៃ សេចក្ដីសំរេចនេះ ត្រូវផ្អែកតាមការណែនាំរបស់ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ និង ធ្វើឡើងជាជំហាន១ ស្របតាមសមត្ថភាព និង ធនធានដែលមាន ។

ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ត្រូវធ្វើការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ដើម្បីសំរបសំរួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធអំពីការធ្វើប្រតិភូកម្មអំណាច និង ការអនុវត្តនូវ តួនាទី មុខងារ អំណាចរបស់ស្រុកទាំងពីរឱ្យបានសមស្រប ។

**ប្រការ ៦.–**

ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវធ្វើប្រតិភូកម្មអំណាច និង ភារកិច្ចដល់ស្រុកទាំងពីរអោយបានសមស្រប ក្រោមការសំរបសំរួលពីក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង អភិបាលខេត្តសាមី ។

**ប្រការ ៧.–**

ការធ្វើប្រតិភូកម្មអំណាច ដែលធ្វើឡើងដោយក្រសួងស្ថាប័ននីមួយ១ ត្រូវភ្ជាប់ជាមួយនូវការបណ្ដុះបណ្ដាលការកសាងសមត្ថភាព និង ការផ្ដត់ផ្ដង់មធ្យោបាយ សំភារៈ ថវិកាសមស្របសំរាប់ស្រុកទាំងពីរ ។

**ប្រការ ៨.–**

ស្រុកនីមួយ១ត្រូវដឹកនាំដោយអភិបាលស្រុក ០១ រូប អមដោយអភិបាលរងស្រុកមួយចំនួន ជាជំនួយការ ។

ការកំណត់ចំនួនអភិបាលរងស្រុក និង ការបែងចែកភារកិច្ច របៀបរបបធ្វើការងាររបស់អភិបាល អភិបាលរងស្រុកត្រូវកំណត់ដោយ ប្រកាសរបស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**ប្រការ ៩.–**

សាលាស្រុក ជាទីចាត់ការរដ្ឋបាលរបស់ស្រុក និង ត្រូវគ្រប់គ្រងដោយផ្ទាល់ពីអភិបាលស្រុក មានជំនួយពីប្រធានមន្ទីរស្រុក ។

ប្រធានមន្ទីរស្រុក មានអនុប្រធានមន្ទីរ ០១ រូប ជាជំនួយការ ។

សាលាស្រុក មានការិយាល័យ មួយចំនួន ជាជំនួយការ ។

ការរៀបចំ និង ការប្រព្រឹត្តិទៅនៃសាលាស្រុក ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

**ប្រការ ១០.-**

ស្រុកនីមួយៗត្រូវបង្កើតឱ្យមានក្រុមប្រឹក្សាស្រុក ។

ក្រុមប្រឹក្សាស្រុក មានអភិបាលស្រុកជាប្រធាន និងមានអភិបាលរងស្រុក ប្រធានមន្ទីរស្រុក ប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី ១ ជំទប់ទី ២ គ្រប់ឃុំចំណុះស្រុក ជាសមាជិក ។

ក្រុមប្រឹក្សាស្រុក ជាអង្គការដែលអភិបាលស្រុក ត្រូវពិគ្រោះយោបល់លើបញ្ហាដែលទាក់ទងនឹង ៖

- ផែនការអភិវឌ្ឍន៍ស្រុក
- គំរោងមេ ផែនការប្រើប្រាស់ដីធ្លី
- គំរោងចំណាយថវិកា
- ការងារផ្សេងទៀត ដែលអភិបាលស្រុកយល់ឃើញថាចាំបាច់ ។

ការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាស្រុក និង ទំនាក់ទំនងរវាងអភិបាលស្រុក និង ក្រុមប្រឹក្សាស្រុក ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

**ប្រការ ១១.-**

ត្រូវបង្កើតអោយមាន ការិយាល័យ " ច្រកចេញចូលតែមួយ " ចំណុះសាលាស្រុកនីមួយៗ ។ ការិយាល័យ "ច្រកចេញចូលតែមួយ" មានសមត្ថកិច្ចផ្តល់ជូនប្រជាពលរដ្ឋ និងសហគ្រាស នូវសេវាកម្មរដ្ឋបាល ដែលប្រជាពលរដ្ឋត្រូវការជាប្រចាំ អោយបានទាន់ពេលវេលា មានតម្លាភាព និង តាមនីតិវិធីសាមញ្ញ ។

ការិយាល័យនេះត្រូវរៀបចំប្រមូលផ្តុំសេវាកម្ម និង នីតិវិធីរដ្ឋបាលមួយចំនួននៅកន្លែងតែមួយ ។

ការិយាល័យនេះ ជាកន្លែងអតិថិជនត្រូវបានទទួលទម្រង់បែបបទ និង ទទួលពត៌មានគ្រប់គ្រាន់ច្បាស់លាស់ ស្តីពីការផ្តល់សេវាកម្មសាធារណៈផ្សេងៗ នឹងត្រូវបង់កម្រៃសេវាកម្ម ឬ អាករផ្សេងៗ និង ជាកន្លែងផ្តល់នូវលទ្ធផលសំរេចជាផ្លូវការលើសេចក្តីស្នើសុំដល់អតិថិជនវិញ ។

ការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យ " ច្រកចេញចូលតែមួយ " ត្រូវកំណត់ដោយប្រកាស

របស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និង មានកិច្ចសហការពីក្រសួងស្ថាប័នដែលពាក់ព័ន្ធ ។

**ប្រការ ១២.-**

ដើម្បីលើកកំពស់អភិបាលកិច្ចល្អ នៅស្រុកនីមួយៗត្រូវបង្កើតអោយមានការិយាល័យ " ប្រជាពលរដ្ឋ " ដែលមានសមត្ថកិច្ចទទួលពាក្យបណ្តឹង និង ផ្តល់ពត៌មានជូនប្រជាពលរដ្ឋ ក្រុមហ៊ុន សហគ្រាស និង អង្គការសង្គមស៊ីវិល ក្នុងករណីមានភាពមិនប្រក្រតី ឬកំហុសឆ្គងរបស់បុគ្គលិកដែលបំរើការងារក្នុងរដ្ឋបាលស្រុក ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃការិយាល័យ " ប្រជាពលរដ្ឋ " ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

**ប្រការ ១៣.-**

ក្រសួងស្ថាប័នពាក់ព័ន្ធនានា ត្រូវចាត់មន្ត្រីមានសមត្ថភាពឱ្យទៅបំរើការងារនៅក្នុងការិយាល័យនានារបស់ស្រុក ដើម្បីជួយអភិបាលស្រុក ក្នុងការអនុវត្តន៍កិច្ចការតាមជំនាញរបស់ខ្លួន ។

**ប្រការ ១៤.-**

បុគ្គលិក នៃការិយាល័យនានារបស់ស្រុក ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និង ដឹកនាំរបស់អភិបាលស្រុក ។

មន្ត្រីរាជការរបស់ក្រសួងស្ថាប័ន ដែលបំរើការងារនៅស្រុកទាំងពីរនេះ ត្រូវស្ថិតនៅជាមន្ត្រីរាជការរបស់ក្រសួងស្ថាប័នដើមដដែល ប៉ុន្តែការដាក់ពិន្ទុ តំឡើងថ្នាក់ និង ការតែងតាំងក្នុងមុខតំណែង ត្រូវតែមានការយល់ព្រមពីអភិបាលស្រុក ។

រាល់សេចក្តីណែនាំលើការងារជំនាញពីក្រសួងស្ថាប័នសាមី ត្រូវធ្វើតាមរយៈមន្ទីររបស់ខ្លួននៅថ្នាក់ខេត្ត និង ត្រូវឆ្លងកាត់អភិបាលស្រុក ដែលទទួលខុសត្រូវរៀបចំការអនុវត្តន៍ និង រាយការណ៍ជូនសាលាខេត្ត និង មន្ទីរជំនាញរបស់ក្រសួងស្ថាប័ននោះ ។

**ប្រការ ១៥.-**

ក្នុងរយៈពេលដំបូងនៃការអនុវត្តន៍សាកល្បង អភិបាលស្រុកត្រូវរៀបចំគំរោងចំណាយថវិកាតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ១៦.-**

ក្រសួងមហាផ្ទៃ គឺជាស្ថាប័ននៅថ្នាក់ជាតិ ក្នុងការសំរបសំរួលអនុវត្តគំរោងសាកល្បងនេះ ។

ក្នុងការអនុវត្តទីគំរោងសាកល្បងនេះ ក្រសួងមហាផ្ទៃត្រូវធ្វើការពិគ្រោះ ពិភាក្សាជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងក្រសួងស្ថាប័នពាក់ព័ន្ធនានា ។

ក្នុងការអនុវត្តទីគំរោងសាកល្បងនេះ ក្រសួងមហាផ្ទៃអាចទទួលជំនួយគាំទ្រ ខាងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីអ្នកផ្តល់ជំនួយក្នុង និង ក្រៅប្រទេស ។

**ប្រការ ១៧.-**

ថ្នាក់ខេត្តត្រូវបង្កើតអោយមាន គណៈកម្មការសំរបសំរួលមួយ ដែលមានសមាសភាព ÷

- អភិបាលខេត្ត ឬ អភិបាលខេត្តរង ១ រូប ដែលតែងតាំងដោយអភិបាលខេត្ត ជាប្រធាន
- តំណាង ១ រូប មកពីក្រសួងមហាផ្ទៃ ជាសមាជិក
- តំណាង ១ រូប មកពីគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ជាសមាជិក
- តំណាង ១ រូប មកពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ជាសមាជិក
- តំណាង ១ រូប មកពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក
- តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគំរោងនេះ ជាសមាជិក
- តំណាងមកពីមន្ទីរជំនាញដែលពាក់ពន្ធ័នឹងគំរោងនេះ ជាសមាជិក

គណៈកម្មការសំរបសំរួល ត្រូវមានការិយាល័យរបស់ខ្លួនក្នុងសាលាខេត្តបាត់ដំបង និង សាលាខេត្តសៀមរាប ព្រមទាំងមានបុគ្គលិកចាំបាច់សំរាប់ការិយាល័យនេះ ។ ក្នុងការអនុវត្តការងារ សមាជិកគណៈកម្មការត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានគណៈកម្មការ ។ ប្រធានគណៈកម្មការត្រូវធ្វើការពិភាក្សាជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដើម្បីកំណត់នូវតំណាងក្រសួងស្ថាប័ន និង មន្ទីរជំនាញពាក់ព័ន្ធ ដែលត្រូវចូលរួមក្នុងគណៈកម្មការនេះ ។ មុនចាប់ផ្តើមបំពេញការងារ គណៈកម្មការត្រូវរៀបចំរបៀបរបបធ្វើការងារ របបប្រជុំ និង របបរាយការណ៍ ឱ្យបានសមស្រប ។

**ប្រការ ១៨.-**

គណៈកម្មការសំរបសំរួលថ្នាក់ខេត្ត មានភារកិច្ចគាំទ្រ និង ត្រួតពិនិត្យការអនុវត្តទីគំរោងសាកល្បងនេះ ដោយអនុលោមតាមស្មារតីនៃសេចក្តីសំរេចនេះ ច្បាប់ និង លិខិតបទដ្ឋាននានាជាធរមាន ។

**ប្រការ ១៩.-**

ក្រសួងមហាផ្ទៃមានភារកិច្ចធ្វើសេចក្តីរាយការណ៍រៀងរាល់ ៣ ខែម្តង ជូនគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល អំពីដំណើរការ អនុវត្តគំរោងនេះ និង

សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ធ្វើសេចក្តីរាយការណ៍ជូនគណៈរដ្ឋមន្ត្រី អំពី អនុសាសន៍ បទពិសោធន៍ នៃការអនុវត្តន៍គំរោងនេះ ដើម្បីពង្រីកការរៀបចំគ្រប់គ្រងស្រុក នៅទីប្រជុំជនខេត្ត ដទៃទៀត ។

**ប្រការ ២០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ អភិបាល ខេត្តបាត់ដំបង និងអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុក អនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

__ចម្លងជូន :__

- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- ក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- សាលាខេត្តសៀមរាប
- សាលាខេត្តបាត់ដំបង
- ឯកសារ-កាលប្បវត្តិ